# ការសំភាសន៍របស់បងឈ្មោះផាន តឿយ

កះ អ្នកដែលសំភាសន៍ហួន ឡាយហុក ខះ អ្នកដែលត្រូវបានគេសំភាសន៍ផាន តឿយ

កះ ជាដំបូងសូមថ្លៃអំរគុណដល់បងដែលបានអោយខ្ញុំសំភាសន៍បងថ្ងៃនេះណាស់បង។

ខះ បាទ!។

កះ
ហើយការសំភាសន៍គឺខ្ញុំយកទៅចាក់ផ្សាយនៅក្នុងគេហទំព័ររបស់វិទ្យាល័យនៅអាមេរិចដែលមានឈ្មោះថាBYUអញ្ចឹងណាស់។

ខះ បាទ!។

កះ
ហើយដោយសារសកលវិទ្យាល័យមានបំណងមួយចង់រក្សាជីវប្រវត្តិរបស់ប្រជាជនខ្មែរយើងទាំងអស់គ្នាដាក់ចូលក្នុងវេបសាយហ្នឹងទៅទុកអោយកូនចៅជំនាន់ក្រោយៗទៀតស្គាល់ពីយើងហើយពីជីដូនជីតាហើយនិងហេតុការណ៍ដែលបងកើតឡើងនៅក្នុងជីវិតរបស់បងណាស់។

ខះ បាទ!។

កះ បាទ!
អញ្ចឹងចុះបងមានចង់ថាបងអាចអោយខ្ញុំដាក់ការសំភាសន៍នេះទៅក្នុងគេហទំព័ររបស់សាលាបានអត់បាន។

ខះ បានលោកគ្រូបាន។

កះ អញ្ចឹងសូមបងអីរៀបរាប់ឈ្មោះពេញរបស់បងឈ្មោះអីគេ។

ខះ ឈ្មោះខ្ញុំផ្ទាល់ឈ្មោះផាន់ តឿយ។

ក៖ ផាន់ ទើយ។

ខ៖ បាទ!។

ក៖ បាទ! ចុះបងមានឈ្មោះហៅក្រៅអត់។

ខ៖ អត់មានទេឈ្មោះក្នុងបញ្ជីម៉េចអត់មានក្រៅទេ។

ក៖ ចង់ថាអ្នកជិតផ្ទះគេមានហៅអីផ្សេងទេចង់និយាយអញ្ចឹងណាស់។

ខ៖ គេហៅទើយ។

ក៖ អញ្ចឹងណើ។

ខ៖ បាទ!។

ក៖ អត់មានគេហៅអីផ្សេងពីហ្នឹងទេ។

ខ៖ បាទ! អត់មានទេ។

ក៖ បាទ! អញ្ចឹងបងកើតឆ្នាំណា។

ខ៖ ខ្ញុំកើតឆ្នាំ១៩៨៣។

ក៖ អ៎! ៨៣ណោះ។

ខ៖ បាទ!។

ក៖ ហើយចុះថ្ងៃខែមានចាំអត់។

ខ៖ ខែដូចមិនសូវចាំទេខែ។

ក៖ ថ្ងៃ?។

ខ៖ ថ្ងៃកើតថ្ងៃពុធ។

កៈ ហើយចុះបើសិនជារាប់តាមចន្ទ័កតិមានន័យថារាប់តាមជូន ឆ្លូវ ខាល ថោះបងកើតឆ្នាំអីគេ។

ខៈ ខ្ញុំកើតឆ្នាំកុរ។

កៈ ឆ្នាំកុរណោះ។

ខៈ បាទ!។

កៈ អ៎!ឆ្នាំកុរ។ បាទ!ហើយចុះបងសព្វថ្ងៃបងប្រកបមុខរបបរអីគេដែល។

ខៈ ខ្ញុំមុខរបបរើសអេតចាយហ្នឹងលោកគ្រូ។

កៈ អ៎! រើសអេតចាយ។

ខៈ បាទ!។

កៈ បាទ! អញ្ចឹងចុះខ្ញុំចង់ស្គាល់ឈ្មោះម្ដាយឪពុករបស់បងហ្នឹង។

ខៈ បាទ!។

កៈ គាត់ឈ្មោះអីគេ។

ខៈ ម្ដាយឈ្មោះម៉ៅ ពៅ។

កៈ ម៉ៅ ពៅចុះឪពុក។

ខៈ ឪពុកស្លាប់ប៉ុន្តែឈ្មោះចៀម ផាត។

កៈ ចៀម ផាត។

ខៈ បាទ!។

កៈ ចុះម្ដាយឪពុកពីមុខគាត់ប្រកបរមុខរបបរអីគេ។

ខ៖ ពីមុខគាត់លក់បន្លែតិចតួចហ្នឹងលោកគ្រូ។

ក៖ លក់បន្លែ។

ខ៖ បាទ!។

ក៖ គាត់លក់នៅណាវិញ។

ខ៖ លក់នៅផ្សារច្បារអំពៅ។ លក់បានមួយហូបៗហ្នឹង។

ក៖ បាទ!។

ខ៖
ជំនាន់មុខកាលខ្ញុំនៅលុយថ្លៃលុយក្រដាសមួយរៀលពីររៀលក្រដាស១០រៀលលុយយើងពីមុខៗលោកគ្រូហ្នឹងហើយគាត់លុយបន្លែត្រកួលប្រលឹតជួបណាគាត់លក់អំពៅអីហ្នឹងកាប់កង់ៗយកទៅលក់លាយគ្នាអញ្ចឹង។

ក៖ អញ្ចឹងចុះឪពុករបស់បងហេតុអីបានជាគាត់ គាត់ស្លាប់អោយសារអីគេ។

ខ៖ គាត់ហូបស្រាពេក។

ក៖ អ៎! អញ្ចឹង។

ខ៖ បាទ!
គាត់ហូបស្រែរាល់ថ្ងៃអោយតែកំពុងធ្វើបាយសំឡរអញ្ចឹងទៅគាត់ហូបហើយគាត់ស្លាប់ដោយសារតែស្រាហ្នឹង។

ក៖ អ៎!។

ខ៖ បាទ! ក្រិនថ្លើមក្រិនអីណាគាត់។

ក៖ អ៎! អញ្ចឹង។

ខ៖ បាទ!

កៈ ពេលគាត់ស្លាប់បងមានចាំថាគាត់ស្លាប់នៅអាយុប៉ុន្មានអត់។

ខៈ កាលគាត់ស្លាប់ខ្ទង់អាយុ៤០ជាង។

កៈ ៤០ជាងគាត់ស្លាប់ណោះ។

ខៈ បាទ!៤២ ៤៣អីហ្នឹង។

កៈ អ៎!។

ខៈ បាទ!។

កៈ ហើយចុះម្ដាយរបស់បងគាត់នៅរស់អត់។

ខៈ នៅតើ។

កៈ គាត់អាយុប៉ុន្មានឆ្នាំហើយ។

ខៈ គាត់អាយុ៥០ជាង។

កៈ ៥០ជាងហើយ។

ខៈ បាទ!។

កៈ ចុះសព្វថ្ងៃហ្នឹងគាត់រកអីគេ។

ខៈ
គាត់រើសអេតចាយដែលហ្នឹងជូនណាគាត់រាងឈឺគាត់ចាស់គាត់មិនសូវដើរទៅរើសអេតចាយដូចមុខទេ។

កៈ អ៎!។

ខៈ បាទ! អោយលុយគាត់គ្រាន់តែទិញអង្កអីហូបហ្នឹងណាស់។

កៈ បាទ!។

ខ៖ បាទ!។

ក៖ ចុះបងមានចាំឈ្មោះឪពុករបស់ឪពុកបងជីដូនជីតា។

ខ៖ អត់ចាំទេ។

ក៖ ស្គាល់តែឪពុក។

ខ៖ ស្គាល់តែឪពុកមួយ។

ក៖ ចុះតាអត់ចាំទេអត់ដឹងតាឈ្មោះអីទេ។

ខ៖ បាទ! អត់ដឹងទ្បូតែសួរម៉ែ។

ក៖ អ៎! អញ្ចឹង។

ខ៖ បាទ!។

ក៖ ហើយអញ្ចឹងចុះបងសព្វថ្ងៃមានប្រពន្ធនៅ។

ខ៖ មានហើយ។

ក៖ មានហើយប្រពន្ធបងឈ្មោះអីគេ។

ខ៖ ប្រពន្ធម៉េចហ្នឹង។

ក៖ បាទ! ឈ្មោះអីគេ។

ខ៖ ម៉ាក់ សុឃុម។

ក៖ ម៉ាក់ សុឃុម។

ខ៖ បាទ!។

ក៖ បាទ! មានកូនប៉ុន្មាននាក់។

ខ៖ មានកូនប្រាំនាក់។

ក៖ ប្រាំនាក់។

ខ៖ បាទ!។

ក៖ កូនទីមួយឈ្មោះអីគេ។

ខ៖ ម៉ាក់ ពី។

ក៖ ម៉ាក់ ពី។ហើយគាត់អាយុប៉ុន្មានឆ្នាំហើយ។

ខ៖ អាយុ១៨ឆ្នាំ។

ក៖ អាយុ១៨ឆ្នាំហើយ។

ខ៖ បាទ!។

ក៖ បាទ! ហើយចុះរាល់ថ្ងៃគាត់ធ្វើអីគេម៉ាក់ ពី។ គាត់នៅរៀនសូត្ររឺក៏ម៉េច។

ខ៖ ឈប់រៀនហើយហ្នឹង។

ក៖ គាត់ធ្វើអីគេអញ្ចឹង។

ខ៖ គាត់ដើរគេប្រែធ្វើអីចេះតែធ្វើហ្នឹងទៅ។

ក៖ ដើម្បីយកលុយ។

ខ៖ បាទ! ដើម្បីអោយលុយអ្នកផ្ទះពួកខ្ញុំទិញអីហូបអញ្ចឹងទៅទិញអង្គអី។

ក៖ បាទ! ហើយចុះកូនទីពីរឈ្មោះអីគេ។

ខ៖ តឿយ សុលាភ។

ក៖ តឿយ សុលាភ។ អាយុប៉ុន្មានឆ្នាំហើយ។

ខ៖ ៩ឆ្នាំ។

ក៖ ៩ឆ្នាំហើយតែនៅរៀនតើអី។

ខ៖ នៅ។

ក៖ រៀនសាលាណាដែល។

ខ៖ វាលស្បៅលោកគ្រូ។

ក៖ វាលស្បៅ អ្នកណាជូនទៅរៀន។

ខ៖ ខ្ញុំអ្នកជូនរាល់ព្រឹកដាក់រទេះអេតចាយហ្នឹង។

ក៖ អ៎!។

ខ៖ បាទ!។

ក៖ ហើយចុះបន្ទាប់មកទៀត។

ខ៖ បន្ទាប់មកទៀតមួយស្រីនោះ។

ក៖ អ៎!ហើយគាត់អាយុប៉ុន្មានឆ្នាំហើយ។

ខ៖ អាយុ៦ឆ្នាំ។

ក៖ ហើយគាត់នៅរៀនដែលនោះ។

ខ៖ នៅរៀន។

ក៖ រៀននៅសាលាជាមួយគ្នាមែន។

ខ៖ សាលាជាមួយតើលោកគ្រូ។

ក៖ បន្ទាប់មកបានកនស្រីចុងក្រោយនេះ។

ខ៖ ហ្នឹងហើយ។

ក៖ អាយុប៉ុន្មានឆ្នាំ។

ខ៖ ចុងក្រោយអីនៅអាពៅមួយទៀតនេះ៥ឆ្នាំ។

ក៖ អ៎! នេះ៥ឆ្នាំ។

ខ៖ បាទ!។

ក៖ អ៎! ចុះពៅ។

ខ៖ អាពៅ៣ឆ្នាំ។

ក៖ អាពៅប្រុសរឺស្រី។

ខ៖ ប្រុស។

ក៖ ហើយចុះបងមានស្គាល់ម្ដាយឪពុករបស់ប្រពន្ធបងមានស្គាល់ឈ្មោះអត់។

ខ៖ ស្គាល់។

ក៖ ឈ្មោះអីគេ។

ខ៖ ម្ដាយឈ្មោះម៉ាក់ សុខន។

ក៖ ម៉ាក់ សុខន។ ចុះឪពុក។

ខ៖ ឪពុកមៀចម៉ាក។

ក៖ មៀច ម៉ាក។ ចុះមានដឹងទេហេតុអីបានជាឪពុកគាត់ស្លាប់ខាងប្រពន្ធ។

ខ៖ គាត់កើតក្លូន។

ក៖ អ៎!កើតក្លូន។

ខ៖ បាទ!។

ក៖ គេមើលមិនជាមែន។

ខ៖ គាត់ដេកទុលពោះអត់មានអ្នកណាគេទាន់តែដឹងតែគាត់កើតក្លួន។

ក៖ ចុះពេលហ្នឹងបងទាន់ដែលគាត់ស្លាប់ហ្នឹងអត់។

ខ៖ អត់ទាន់ផង។

ក៖ លឺគេនិយាយដែលតើអី។

ខ៖ បាទ! លឺគេនិយាយ។

ក៖ អ្នកណាគេនិយាយប្រាប់។

ខ៖ ប្រពន្ធ។

ក៖ អ៎! ប្រពន្ធជាអ្នកនិយាយប្រាប់ណោះ។

ខ៖ បាទ!ហ្នឹងហើយ។

ក៖ អ៎! អញ្ចឹងហើយអញ្ចឹងចុះខាងម្ដាយគាត់នៅរស់ដែលតើអីម្ដាយខាងប្រពន្ធ។

ខ៖ ស្លាប់ទាំងពីរ។

ក៖ ស្លាប់ទាំងពីរ។

ខ៖ បាទ!។

ក៖ គាត់កើតនៅគេបានគាត់ស្លាប់។

ខ៖ គាត់ហូបម្ដាយ។

ក៖ ម្ដាយហូបស្រា(ផឹកស្រា)។

ខ៖ ម្តាយក្មេកគាត់ហូបស្រា។

ក៖ ហូបស្រាក៏ស្លាប់ទៅ។
ហើយចុះមានដឹងថាម្តាយប្រពន្ធពីមុខគាត់ប្រកបមុខរបរអីគេដែលដើម្បីចិញ្ចឹមជីវិតណាស់។

ខ៖
គាត់ដើរលក់ស្អីៗដើរកោសខ្យល់អោយគេអញ្ចឹងទៅជូនណាគាត់ដើរលក់ផ្លែអំពឹលទឹកអីគេដាំដើរបេះស្លឹកបាស់អីគាត់ចេះតែដើរចេះផ្សំយកទៅលក់។

ក៖ បាទ!។ហ្នឹងហើយញ្ចឹងពេលដែលបងរៀបការជាមួយប្រពន្ធ។

ខ៖ បាទ!។

ក៖ កើតអីបានស្គាល់គ្នានីពេលហ្នឹងកើតអីបានស្គាល់គ្នា។

ខ៖ អ៎
ខ្ញុំទៅលេងផ្ទះគាត់ខ្ញុំស្គាល់គាត់ដែលហ្នឹងទៅលេងផ្ទះគាត់អញ្ចឹងទៅទៅលេងពីរថ្ងៃមិនដឹងមានចិត្តក៏ស្រលាញ់គាតទៅបានយកគ្នាសព្វថ្ងៃហ្នឹង។

ក៖ បាទ!
ហើយចុះពេលដែលចង់ថាឃើញគាត់ដំបូងឡើយបន្ទាប់មកបានបងមានចិត្តស្រលាញ់គាត់ហើយបន្ទាប់មកទៀតក៏បងទៅប្រាប់ម្តាយឪពុកចូលស្តីដណ្តឹងកាលហ្នឹងប្រាប់ម្តាយអោយចូលស្តីដណ្តឹងមែន។

ខ៖ បាទ!
កាលហ្នឹងប្រាប់ម៉ែខ្ញុំប្រាប់បងគេព្រោះគេគ្នាម៉ែឪផងចូលទៅសុំស្រលាញ់ប្អូនបងឯងបាទ។
គាយ់ថាធ្វើម៉េចទៅអោយតែចេះស្រលាញ់គ្នា។

ក៖ បាទ!
ហើយចុះនៅពេលដែលបងទៅប្រាប់ម្តាយខាងបងម្តាយខាងបងគាត់និយាយម៉េចដែរ។

ខ៖
គាត់ព្រមគាត់តាមខ្ញុំដែរអោយខ្ញុំស្រលាញ់កូនគេហើយគេស្រលាញ់យើងគាត់ថាគេស្រលាញ់យើងស្រលាញ់ទៅកុំអោយគេធ្វើបាបធ្វើអីថាមិនអីទេខ្ញុំសព្វថ្ងៃមិនទេយូរឆ្នាំខ្ញុំយកទាំងពី២០១៥រហូតដល់ឥឡូវ២០១៨។

ក៖ អញ្ចឹងចុះបងពេលដែលរៀបការ កាលហ្នឹងបានរបការអត់។

ខ៖ សែន។

ក៖ គ្រាន់តែសែនធម្មតាទៅ។

ខ៖ សែនធម្មតាព្រោះយើងអត់លោកគ្រូ។

ក៖ ហ្នឹងហើយកាលហ្នឹងសែននៅណា។

ខ៖ នៅក្រោមនៅផ្ទះបឹងក្រោម។

ក៖ នៅបឹងក្រោមហ្នឹងនៅភូមិអីគេស្រុកអីគេ។

ខ៖ ភូមិស្វាយតាអុកស្រុកកៀនស្វាយឥឡូវគេកាត់ចូលក្រុមហើយលោកគ្រូរាជធានីភ្នំពេញ។

ក៖ ចុះពីមុខអីគេ។

ខ៖ ពីមុខខណ្ឌមានជ័យ។ បាទ!។

ក៖ ហើយចុះនៅដែលបងចង់បងឃើញគាត់ភ្លែមស្រលាញ់គាត់ភ្លែមរឺក៏ម៉េច។

ខ៖ អត់ទេនៅទាក់ទងសិនហ្នឹងនៅប្រហែលជាកន្លះខែជាងបានចូល។

ក៖ ពេលហ្នឹងឃើញគាត់ក៏ស្រលាញ់គាត់ទៅ។

ខ៖ បាទ!។

កៈ បាទ!
ហើយចុះនៅពេលបងមានអារម្មណ៍ថាស្រលាញ់គាត់ពេលហ្នឹងបងមានបំណងថាចង់រៀបការជាមួយគាត់ទេ។

ខៈ បាទ! ហ្នឹងហើយចង់។

កៈ
ចង់ថាហ្នឹងបងឃើញគាត់ម៉េចបានដែលវងគិតថាចងថាការជាមួយគាត់ដូចថាគាតមនុស្សម៉េចដែល។

ខៈ
ខ្ញុំឃើញគាត់មនុស្សគាត់អាចយកទៅជាថ្ងៃអនាគតបាននិយាយគាត់ចេះជួយនេះគាត់ឧស្សាហ៍អញ្ចឹងណាស់លោកគ្រូ។

កៈ បាទ!។

ខៈ បាទ!ហើយបានខ្ញុំមានចិត្តលើគាត់ទៅ។

កៈ ហើយចុះនៅពេលដែលចង់ថាឃើញគាត់ឧស្សារហ៍ព្យាយាមមែនអត់។

ខៈ បាទ!ហ្នឹងហើយ។

កៈ ចុះពេលដែលបងយកគាត់ហើយតើគាតើឧស្សារហ៍ព្យាយាមមែនអត់។

ខៈ ឧស្សាហ៍ព្យាយាមធ្វើកិច្ចក្នុងផ្ទះធ្វើក្រៅអីបានយើងអាចពឹងពាក់គាត់បាន។

ខៈ ហ្នឹងហើយ។

កៈ
ហើយចុះពេលដែលបងស្រលាញ់គាត់ហើយបន្ទាប់ពីរៀបការហើយពេលរៀបការហើយបងស្នាក់នៅណាវិញ។

ខ៖
ខ្ញុំនៅកន្លែងផ្ទះគាត់ជួលហ្នឹងនៅបណ្ដោះអាសន្នប្រហែលជិតមួយខែជាងដែរហើយបានខ្ញុំនាំគាត់មកផ្ទះរៀបចំសែនម៉ងទៅ។

ខ៖ បាទ!។

ក៖
អត់ទេខ្ញុំចង់ដឹងថាអញ្ចេកពេលដែលបងរៀបចំសែនហើយការហើយបងនៅផ្ទះនៅណាផ្ទះខ្លួនឯងរឺនៅជាមួយបងប្អូនរឺក៏។

ខ៖ អត់ទេផ្ទះផ្ទាល់ខ្លួនឯងម៉ងសល់លុយតិចតួចខ្ញុំធ្វើកូនខ្ទមនៅ។

ក៖ កាលហ្នឹងនៅណា។

ខ៖ នៅក្រោមលោកគ្រូ។

ក៖ នៅភូមិហ្នឹងម៉ង។

ខ៖ បាទ! នៅភូមិហ្នឹងម៉ង។

ក៖ ប៉ុន្តែការជាមួយគាត់ការនៅផ្ទះគាត់ផ្ទះបងគាត់មែន។

ខ៖ ផ្ទះខ្ញុំ។

ក៖ អញ្ចឹងបានន័យថាគាត់មកការខាងបងវិញ។

ខ៖ បាទ!។

ក៖ អ៎!យល់អញ្ចឹង។ អញ្ចឹងចុះកាលហ្នឹងពេលការហើយអញ្ចឹងបានមកនៅភូមិនេះ។

ខ៖ បាទ!។

ក៖ អញ្ចឹងចង់សួរថាអញ្ចេកបងមានបងប្អូនប៉ុន្មាននាក់។

ខ៖ ខ្ញុំមានបងប្អូន៧នាក់។

ក៖ បងប្អូន៧នាក់។

ខ៖ បាទ!។

ក៖ ហើយបងទីមួយគាត់ឈ្មោះអីគេ។

ខ៖ បងទីមួយឈ្មោះផាន់ ស៊ីណាត។

ក៖ ផាន ស៊ីណាត។ គាត់មានគ្រួសារនៅ។

ខ៖ មានប៉ុន្តែលេងគាត់លេងគ្នាឥឡូវមិនដឹងគាត់ទៅដល់ណាទេ។

ក៖ អញ្ចឹង។

ខ៖ បាទ!។

ក៖ ហើយចុះបងទីឈ្មោះអីគេ។

ខ៖ បងទី២ខ្ញុំហ្នឹងហើយ។

ក៖ ចុះបងទីបីប្អូនបន្ទាប់។

ខ៖ ផាន ចិត្តា។

ក៖ ផាន ចិត្តា។ គាត់មានគ្រួសារនៅ។

ខ៖ មានហើយ។

ក៖ មានហើយកាលដែលគាត់ការបងបានចូលរួមមង្គលការគាត់អត់។

ខ៖ បានតើ។

ក៖ គាត់ការនៅណាវិញ។

ខ៖ គាត់ការនៅលើផ្លូវ។

ក៖ អ៎!នៅភូមិអីដែល។

ខ៖ ភូមិហ្នឹងដែលបាទ!។

ក៖ គាត់បានប្រពន្ធអ្នកខាងណាវិញ។

ខ៖ ខាងអ្នកស្វាយរៀង។

ក៖ ស្វាយរៀងចុះបងមានដឹងពេលដែលគាត់ទាក់ទងគ្នាម៉េចដែរ។

ខ៖ អត់ដឹង។

ក៖ ហេតុអីបានស្គាលគ្នា។

ខ៖ ខ្ញុំអត់ដឹង។

ក៖ ប៉ុន្តែពេលការអញ្ចឹងគាត់ប្រាប់បង។

ខ៖
ហ្នឹងហើយដល់ពេលគេការគេប្រាប់ខ្ញុំគេជិតការហើយខ្ញុំមិននឹកស្មានព្រោះយើងអត់ម៉េចមានលទ្ធិភាពការខ្ញុំវាឆ្ងល់ថាមិនដែរអញ្ចឹងទេគ្មានលុយណាដណ្ដឹងកូនគេហ្នឹងហើយហើយគេថាចាំមើលទៅគេប្រាប់ខ្ញុំថាគេបានលុយបានអីណាគេធ្វើការកន្លែងថៅកែលោកគ្រូ។

ក៖ បាទ!។

ខ៖ ប្រហែលជាខ្ចីលុយថៅកែគេមុខម៉េចមិនដឹង។

ក៖ បានកុយការ។

ខ៖ បាទ! បាន៥០០ខាងស្រីគេជួយចេញខ្លះព្រោះការធម្មតាដែលហ្នឹងលោកគ្រូប៉ុន្មានតុហ្នឹង។

ក៖ បាទ!អោយតែបានការ។

ខ៖ បើខ្ញុំសែនសុទ្ធ។

ក៖ សែនសុទ្ធសំខាន់អោយតែបានស្រលាញ់គ្នា។

ខ៖ បានស្រលាញ់គ្នាលោកគ្រូ។

ក៖ បាទ! អ្នកខ្លះកាតមិនបានស្រលាញ់គ្នា។

ក៖ ហើយចុះបន្ទាប់មកទៀតគាត់ឈ្មោះអីគេ។

ខ៖ បន្ទាប់មកទៀតផាន ស៊ីនឿន។

ក៖ ផាន់ ស៊ីនឿនគាត់មានគ្រួសារហើយ។

ខ៖ មានហើយអស់ហើយ។

ក៖ គាត់នៅណាវិញ។

ខ៖ នៅកំពង់ធំ។

ក៖ កំពង់ធំគាត់ប្រកបមុខរបរអីគេ។

ខ៖
គាត់ខាងចិញ្ចឹមមាន់ចិញ្ចឹមជ្រូកខាងប្តីគេអោយចិញ្ចឹមប្តីគេអោយនៅផ្ទះចិញ្ចឹមមាន់ចិញ្ចឹមជ្រូក ប្តីគេរកស៊ីក្រៅដើរបោកស្រូវបោកអីណា។ បាទ!។

ក៖ ហើយចុះបងម៉េចមិនទៅស្រុកដើម្បីចង់សុំរីក៏ខ្ចីមាន់ខ្ចីអីគាត់អីដើម្បីចិញ្ចឹមអញ្ចឹង។

ខ៖ លើកមុខគាត់អោយមកពីរដែលហ្នឹងងាប់អស់។គេអោយមកពីរដែលលោកគ្រូ។

ក៖
បើយើងទៅស្រុកគាត់មានមាន់ស្លាបអញ្ចឹងយើងខ្ចីគាត់សិនខ្ចីចិញ្ចឹមខ្ចីអីសិនយកមាន់ទៅលក់ តាមផ្សារបានលុយច្រើន។

ខ៖ អ៎!ឆ្ងាយណាស់លោកគ្រូអើយ។កំពង់ធំណោះហ្នឹង។

ក៖ ហ្នឹងហើយយើងជិះទៅកំពង់ធំទៅសាកគិតមើលទៅ។

ខ៖ ខ្ញុំដូចខ្លាចចិត្តគេណាស់លោកគ្រូខ្លាចចិត្តប្អូនថ្លៃ។

ក៖ ប្អូនថ្លៃ។

ខ៖ បាទ!។

ក៖ បើយើងគិតថាខ្លាចវាអញ្ចឹងហើយតែបើអត់អញ្ចឹងជួយទាក់ទងគាត់ទៅ។

ខ៖ ហ្នឹងហើយ។

ក៖ មានអីខ្ញុំបងប្អូនឯងស្រួលនិយាយគ្នាទេខ្លាចចិត្តតែបើយើងមិនហ៊ានប្រថុយវាអត់មានតែ។

ខ៖ បាទ!។

ក៖
ឧទាហរណ៍ថាយើងបានខ្ចីមាន់គាត់ហើយយើងចិញ្ចឹងមាន់អោយបានល្អមានពងមានអីហើយយកទៅលក់ទៅហើយយូរៗទៅពងហ្នឹងយោសបានកូនទៀតទៅវាបានកាន់តែច្រើនៗទៅហើយមួយៗគិតជាគីឡូបានលុយច្រើនរើសអៀតចាយវាមិនសូវហាត់វាមិនហាត់ទៅឆ្ងាយៗបើនៅផ្ទះយើងល្អជាង។

ខ៖
មាន់គាត់ដូចមិនសូវច្រើនប៉ុន្មានទេមានតែជ្រូកពីរមាន់ប្រហែល៧ក្បាលអីហ្នឹងហើយលឺគាត់ថាបងប្អូនគាត់មកលេងខាងប្តីវៃកាប់ស៊ីរហូតហ្នឹង។

ក៖ អញ្ចឹងមានអីសល់អញ្ចឹង។

ខ៖ ហ្នឹងហើយ។
គាត់មានចិញ្ចឹមជ្រូកហ្នឹងជ្រូកមានតែពីរពីមុខជ្រូកមាន៥ដល់ពេលគេលក់ជ្រូកធ្វើផ្ទះធ្វើអីអស់ទៅឥឡូវសល់តែពីរក្បាលទេ។

កៈ ស្មានតែមានច្រើនដូចជាកសិដ្ឋានមាន២០។

ខៈ
ហ្នឹងហើយប្អូនថ្លៃក៏ចិត្តបានដែរតែខ្ញុំចេះតែខ្លាចហើយគេអោយម្តងហើយយើងទៅរកគេទៀត
ដូចក្លាចគេ។

កៈ ចុះប្អូនបន្ទាប់ទៀត។

ខៈ ប្អូនបន្ទាប់មកផាន ស៊ីនឿន។

កៈ អុំ!ផាន ស៊ីនឿន។ គាត់មានប្តីប្រពន្ធនៅ។

ខៈ មានហើយ។

កៈ មានហើយ។

ខៈ បាទ!។

កៈ គាត់នៅណាសព្វថ្ងៃហ្នឹង។

ខៈ នៅផ្លូវទៅកំពុងធំដែលនៅបារាយ។

កៈ បាត! ហើតគាត់ប្រកបមុខរបរអីគេ។

ខៈ
គាត់លក់បាបហូយកំប៉ិកំប៉ុកនៅផ្ទះគាត់ហើយប្តីគាតអ្នកដឹកឈើដឹកអីណាដើរដឹកឈើបោះលក់
តាមដេប៉ូគេលោកគ្រូដឹកឈើតូចៗកូនឈើកូនអីហ្នឹង។

កៈ ហើយចុះប្អូនបន្ទាប់ទៀត។

ខៈ ប្អូនបន្ទាប់ទៀតនៅផ្ទះ ខូចជើង។

កៈ គាត់ឈ្មោះអីគេ។

ខ៖ ផាន់ ផាន។

ក៖ កាលហ្នឹងគាត់កើតអីគេបានខូចដើរ។

ខ៖ គាត់ជិះម៉ូតូដើរលេងជាមួយមិត្តភក្រ័ស្លាប់មិត្តមួយហើយនៅតែគាត់ហ្នឹង។

ក៖ អ៎!។

ខ៖ ខូចជើងយូរខែយូរឆ្នាំហើយមិនទាន់វះផងហ្នឹងអត់លុយ។

ក៖ បាទ!។

ខ៖
អោយទៅវះថាអត់មានលុយមានកាក់អញ្ចឹងថាអត់ទៅទេគេទៅរកលុយរកអីមានអីយើងមានប័ណ្ណដេញទៅគេថាទាល់តែ៦ខែបានមើលជើងមួយដងទៀតចូល១ឆ្នាំជាងលោកគ្រូជើងហ្នឹងដែកនៅក្នុងហ្នឹង។

ក៖ អ៎! អញ្ចឹង។

ខ៖ មិនដឹងម៉េច។

ក៖ គាត់ហ្នឹងកូនពៅមែន។

ខ៖ ពៅអីអាហ្នឹងទី៥។

ក៖ អ៎!ឥឡូវបន្ទាប់មកទៀត។

ខ៖ បន្ទាប់មកទៀតផាន យ៉ារី។

ក៖ គាត់មានគ្រួសារហើយ។

ខ៖ មានហើយ។

ក៖ គាត់នៅណាវិញឥឡូវ។

ខ៖ នៅបងប្អូននៅជុំវិញគ្នាទាំងអស់។

ក៖ អញ្ចឹងរាល់ថ្ងៃនេះគាត់ប្រកបមុខរបរអីគេ។

ខ៖ គាត់កម្មករ។

ក៖ កម្មករអីគេ។

ខ៖ កម្មករកន្លែងគេលក់គ្រឿងសំណង់លោកគ្រូ។

ក៖ បាទ!ហើយចុះប្អូនបងបន្ទាប់មកទៀត។

ខ៖ បន្ទាប់មកទៀតផាន ចាន់ណា។

ក៖ ផាន ចាន់ណា។ហ្នឹងកូនពៅណោះ។

ខ៖ ហ្នឹងបន្ទាប់ពៅម៉ង។

ក៖ មានពៅមួយទៀត។

ខ៖ បាទ! មានពៅមួយទៀត។

ក៖ ហើយគាត់មានគ្រួសារហើយ។

ខ៖ មាន។

ក៖ គាត់នៅណា។

ខ៖ គាត់នៅលើហ្នឹងដែរមួយជុំហ្នឹង។

ក៖ អ៎! មួយជុំហ្នឹងម៉ង។ ហើយគាត់មានកូននៅ។

ខ៖ មានកូនមួយហើយមានគ្រួសារតើលោកគ្រូ។

ក៖ អ៎! កូនគាត់ប្រុសរឺស្រី។

ខ៖ ស្រី។

ក៖ ចុះកូន៧។

ខ៖ គាត់មានកូនតែមួយហ្នឹង។ ប្អូន៧អី។

ក៖ ប្អូន៧បង។

ខ៖
ប្អូន៧ចប់ហើយមិនដឹងដល់ណាម៉ែក៏ដើររកខ្ញុំក៏ដើររកបើនិយាយទៅពិបាកណាវាដើរតាមផ្លូវគេស្អំខ្ចីមវាហិតការមិនស្គាល់ផ្ទះមិនស្គាល់អីគេចង់ខូចសរសៃប្រសាទហើយហ្នឹងឥឡូវបាត់ដំណឹងចូលជិត២ខែរាល់ដងមួយខែវាមកផ្ទះវិញហើយជូនកាលខ្ញុំដើរតាមវារហូតដល់មាត់ទន្លេតាខ្មៅនៅកន្លែងមាត់ទន្លេកន្លែងសួនខ្ញុំទៅរកឃើញអញ្ចឹងទៅដឹកមកផ្ទះវិញទៅនៅបាន២ថ្ងៃទៅផ្ទះបាត់ទៀតយើងរកស៊ីដែរចាំមើលតែគាត់ម៉េច។ បាទ!។

ក៖ ហ្នឹងហើយ។

ខ៖ ឥឡូវទៅបាត់ទៀតហើយ។

ក៖ បាត់ឈឹងម៉ង។

ខ៖ បាទឈឹង៣ខែ។

ក៖ មិនដឹងទៅណាទៅណី។

ខ៖ បាទ!
មិនដឹងម៉េចបើរដើរកន្លែងណាក៏ដេកដែរពីមុខឃើញដេកនៅលើបង់កន្លែងសួនហ្នឹងដេកអានឹតប្អូនខ្លាចចិត្តហើយហ្នឹងតែមិនដឹងធ្វើម៉េចបើហាមឃាត់គាត់អត់បាន។

ក៖ ហ្នឹងហើយពិបាកនិយាយគ្នា។

ខ៖ ហ្នឹងហើយ។

កៈ បាទ! ហើយអញ្ចឹងចុះចង់បងមានអានុស្សាវរីអីគេខ្លះជាមួយបងប្អូនបងធ្លាប់លេងអីគេខ្លះជាមួយគ្នាមានទេ។

ខៈ លេងអនុស្សាវរីជាមួយបងប្អូន។

កៈ ចង់និយាយថាលេងអីជុំគ្នា។

ខៈ លេងល្បែងអី។

កៈ ហ្នឹងហើយលេងល្បែងលេងអីជុំគ្នាធ្លាប់មានទេ។

ខៈ លេងមានតែលេងបោះអង្គុញបោះអីហ្នឹង។

កៈ កាលហ្នឹងលេងពេលចូលឆ្នាំម៉ែន។

ខៈ បាទ!ចូលឆ្នាំខោកតែបងប្អូនលេងអោយសប្បាយជូនណាលេងប៉ៀធឹកទឹកធឹកអីហ្នឹងបុណ្យទានអីជួបជុំបងប្អូនលេងសប្បាយណាស់ជួបជុំបងប្អូនមួយដងមួយកាល។

កៈ បាទ! អញ្ចឹងកាលហ្នឹងលេងល្បែងអីគេខ្លះប្រជាប្រិយដូចជាបោះអង្គុញបោះអី។

ខៈ បោះអង្គុញជូនណាលេងប៉ៀធឹកទឹកអញ្ចឹងទៅ។

កៈ បាទ!។

ខៈ ជូនណាលេងទាញព្រ័ត។

កៈ ទាញព្រ័ត។

ខៈ ហ្នឹងហើយ។ហើយលេងបិទផ្កាចំប៉ាផ្កាចំពីអីណា។

កៈ
ពេលហ្នឹងចង់និយាយថាពេលហ្នឹងលេងតែជាមួយក្រុមគ្រួសារបងប្អូនរបស់បងរឺលេងជាមួយអ្នកដ៏ទៃជិតខាង។

ខៈ អ្នកដ៏ទៃក៏លេងរួចគ្នាសប្បាយរួចគ្នាទាំងអស់ហ្នឹង។

កៈ បាទ! ហើយចុះអញ្ចឹងចង់សួរបងថាបងរៀនថ្នាក់ទីប៉ុន្មានហើយ។

ខៈ រៀនបានថ្នាក់ទី៦លោកគ្រូ។

កៈ ទី៦ហើយ។

ខៈ បាទ!។

កៈ ចុះកាលហ្នឹងបងរៀននៅសាលាណាដែល។

ខៈ
សាលាបឋមសិក្សាបឹងត្របែកខាងត្បូងផ្លូវផ្សារដើរថ្កូវលោកគ្រូមុខផ្ទះខ្ញុំក្បាល់ខ្ពាល់តើគេម៉ែខ្ញុំលក់ដីលក់ផ្ទះមកនៅសហាគមន៍អញ្ចឹងទៅសហាគមន៍ពិបាកដែលគេរកតែដេញខ្ញុំមិនដឹងទៅនៅណាទេលោកហើយ។

កៈ អ៎! អញ្ចឹង។

ខៈ បាទ! ទាំងអស់គ្នា។

កៈ ហ្នឹងហើយចុះបងកើតបានឈប់រៀនថ្នាក់ទី៦។

ខៈ
ខ្ញុំនិយាយទៅឃើញម៉ែឪខ្វះខាតពេកលោកគ្រូជំនាន់ហ្នឹងខ្វះខាត់ណាស់ប្អូនអីនៅតូចៗខ្ញុំ១៦ឆ្នាំអីឃើញម៉ែជួនកាលបាយអត់មានអីហូបក៏មានដែលជួនកាលខ្ញុំចាក់ទឹកត្រីហូប។

កៈ បាទ!។

ខ៖ ជួលកាលអំបឹលដាក់ទឹកហត់ទៅជំនាន់ហ្នឹងវេទនាណាស់លោកគ្រូអើយ។

ក៖ បាទ!។

ខ៖ បើមកទាន់បាយទាន់បាយទាន់ទៅបើមិនទាន់អត់ទៅ។

ក៖ អ៎។

ខ៖ វេទនាណាស់មានបាយលាយពោតទៀតលោកគ្រូ។

ក៖ បាទ!។

ខ៖
បាយលាយជាមួយពោតអង្កយើងលាយជាមួយពោតវេទនាណាស់ហើយជំនាន់ហ្នឹងគ្មានលុយគ្មានអីទេស្បែកជើងគ្មានពាក់ផងដើរទៅរៀនទាំងពីផ្ទះនៅក្បាលផ្ទះដើររហូតដល់សាលាជំនាន់ហ្នឹងកំសត់ណាស់ជួនណាខ្ញុំចេញមកខ្ញុំដើររើសសំបកចង់សន្សំលក់អោយគេបានជំនាន់ហ្នឹងបាន៥រៀលទុកអោយអ្នកផ្ទះទិញអីគ្រាន់ផ្សំទិញអីហូបជីវភាពគ្រួសារកាលហ្នឹងវេទនាណាស់មិនដូចឥឡូវទេប៉ាខ្ញុំគាត់ខូចដៃគ្មានធ្វើអីកើតទេកាលជំនាន់ហ្នឹងម៉ែខ្ញុំនៅផ្ទះជួនណាគាត់នឹកឃើញទៅលក់បន្លែគាត់ទៅៗថ្ងៃណាគាត់នៅផ្ទះជំនាន់ហ្នឹងពិបាកណាស់ប្អូនខ្ញុំនៅតូចៗ៦នាក់ហ្នឹង។

ក៖ បាទ!។

ខ៖ វេទនាណាស់។

ក៖
ហើយចុះបងឆ្លងកាត់ការលំបាកហ្នឹងដោយរបៀបណាដែលខិតខំម៉េចដែរដើម្បីជំនះវេទនាទាំងអស់ហ្នឹង។

ខ៖
ខ្ញុំគិតខ្លួនខ្ញុំថាមិនចង់ជួបអាភាពពិបាកដូចពីមុខៗទៀតទេខ្ញុំចង់ពប្រឹងប្រែងអោយមានហូបដូចគេដូចឯងកុំអោយដូចពីមុខៗវេទនាណាស់។

រកមួយថ្ងៃស្អែកឡើងអស់អត់មានអីហូបទៀតទេរាល់ថ្ងៃគ្រាន់តែខ្ញុំមានហូបស្អែកមានសល់ស្អែកមានហូបតិចទៀតចេះតែទប់បានខ្លះបើពីមុខម៉ែឪខ្ញុំមិនថានេះគាត់ទេដូចពិបាកមែន។

ក៖ បាទ!។

ខ៖
ពិបាកណាស់មុនដូចជំនាន់នេះឥឡូវរកនេះបានលុយពីមុខមិនដឹងរកអីទេបេះបន្លែផ្សាំលុយអោយកូនទៅហូបម៉េចគ្រាន់ហូបមិនគ្រាន់ទេលោកគ្រូអើយ។

ក៖ បាទ!ហើយអញ្ចឹងចុះពេលដែលបងនៅកាលនៅរៀនបងមានចាំមិត្តភក្រ័របស់បងទេ។

ខ៖ ចាំតើ។

ក៖ ឈ្មោះអីគាត់។

ខ៖ ឈ្មោះតេង ប៉ូវ៉ាមិត្តភក្រ័ខ្ញុំហើយនិងជា សុភ័ក្រ។ខ្ញុំចាំបានតែប៉ុណ្ណឹងយូរឆ្នាំដែលហើយ។

ក៖ អ៎!ចង់ថាគាត់ជាមិត្តភក្រ័ដែលស្និតស្នាលជាមួយ។

ខ៖ ស្និតស្នាលម៉ងទៅណាទៅទាំងអស់គ្នាទៅដើរលេងទៅណាទៅអី។

ក៖ ជុំគ្នា។

ខ៖
ហ្នឹងហើយប្អូននាក់ប្រាំនាក់មិត្តភក្រ័ច្រើនណាស់ពេលចូលរៀនថ្នាក់ផ្សេងបានមិត្តភក្រ័ផ្សេងទៀតហើយតែពីរនាក់ទៀតភ្លេចឈ្មោះបាត់ហើយ។

ក៖ អ៎!។

ខ៖ បាទ!។

កៈ
អញ្ចឹងចុះបងតាំងពីបងចូលរៀននៅថ្នាក់ទី១រហូតដល់ថ្នាក់ទី៦បងមានក្ដីស្រមៃគិតថាចង់ធ្វើពេលធំឡើងអត់។

ខៈ ខ្ញុំចង់ក្លាយជាខាងម៉ាស៊ីនត្រជាក់។
គំនិតខ្ញុំចង់ក្លាយជាអាហ្នឹងណាស់ប៉ុន្ដែខ្ញុំគ្រួសារខ្វះខាត់អីអញ្ចឹងទៅជំនាន់ហ្នឹង។

កៈ អ៎!អញ្ចឹងជំនាន់នេះគេបង្រៀនម៉ាស៊ីនត្រជាក់តើ។

ខៈ បាទ!។

កៈ កន្លែងរៀនមានតើ។

ខៈ តែឥឡូវខ្ញុំមានគ្រួសារហើយរៀនម៉េចកើតលោកគ្រូ។

កៈ មានគេមិនគិតអំពីគ្រួសារណាបង។ អញ្ចេកបើសិនជាបងទៅកន្លែងគេម៉ាសីនត្រជាក់។

ខៈ បាទ!។

កៈ
គេមានរើសជាងម៉ាស៊ីនត្រជាក់ប៉ុន្ដែមុខហ្នឹងគេអោយយើងធ្វើជាងគេបង្ហាត់បង្រៀនយើងសិនហើយគេអោយយើងធ្វើម៉ងហើយគេអោយលុយប្រាក់ខែអីយើង។

ខៈ អ៎!បាទ! ចុះបើយើងមិនចេះអីសោះ។

កៈ យើងមិនចេះយើងទៅរៀន។

ខៈ ទៅរៀនសិន។

កៈ គេបង្រៀនយើងប៉ុន្ដែបើថាទៅរៀនអញ្ចឹងគេមិនអោយលុយយើងទេបថ្លៃរៀន។

ខៈ អ៎!។

កៈ
ប៉ុន្តែយើងមិនអស់ថ្លៃចំណាយរៀនទេប៉ុន្តែការរៀនមិនអស់លុយពេលយើងរៀនចេះហើយបានអោយលុយតាមក្រោយពេលខ្លះគេបង្រៀនឥតគិតថ្លៃមានន័យថាមិនគិតលុយពីយើងទេ។

ខៈ បាទ!។

កៈ ប្រហែលជាអាចមាន
ដល់ពេលចាំម៉េចៗខ្ញុំទាក់ទងទៅបងវិញបើបងចង់ប៉ុន្តែឃើញម៉ាស៊ីនត្រជាក់ហ្នឹងរលុយបានច្រើន។

ខៈ ហើយពួកម៉ាក់ខ្ញុំជួបលើកមុខខ្ញុំរើសអេតចាយខ្ញុំខ្មាសគេតើគេកំពុងតម៉ាស៊ីនត្រជាក់។

កាលនៅរៀនសុទ្ធតែគិតដូចគ្នាឯងពេលរៀនចប់ចង់ធ្វើអីវិញ
គ្នាខ្ញុំថាចង់ធ្វើម៉ាស៊ីនត្រជាក់ហ្នឹងហើយ។ បាទ! ខ្លះខាងតភ្លើងតអីនៅខាងអគ្គីសនី។

កៈ បាទ!។

ខៈ
សុទ្ធតែមានគំនិតអញ្ចឹងៗឃើញមិត្តភក្រ័គេគ្រាន់បើហើយខ្ញុំរើសអេតចាយអញ្ចឹងខ្ញុំតូចចិត្តខ្លួនឯងមានអារម្មណ៍ខ្មាសខ្លួនឯងម៉ង។

កៈ បាទ!។

ខៈ ឃើញគេម៉េចក៏គេមានមុខមានមាត់មិញយើងលំបាកមិនប្រឹងយកចិត្តទុកដាក់ពេលហ្នឹង។

កៈ ហ្នឹងហើយ។

ខៈ
ហើយរៀនបានតិចទៀតគេកូនអ្នកធូរធារអញ្ចឹងទៅរៀនបានចប់ជួនណាមករៀមបានមួយថ្ងៃដល់ថ្នាក់គ្រូនេះហើយហ្នឹងរៀនក្រោយគេរហូត។

កៈ បាទ!។

ខ៖ បាទ!។

ក៖ ហ្នឹងហើយម៉ាស៊ីនត្រជាក់ដែលខ្ញុំនិយាយហ្នឹងគេមានពីរសាលា។
សាលាមួយគេរៀនយកជំនាញគេរើនជាលក្ខណៈបើតាមខ្ញុំចាំប្រហែលជា៤ឆ្នាំគេរៀនបរិញ្ញបត្រគេរៀនយកសញ្ញាបត្រតែយើងគ្រាន់តែរកដើម្បីជីវភាពប្រចាំថ្ងៃប្រហែលជា២ខែអីរៀនចេះហើយ។

ខ៖ បាទ!។

ក៖ ហ្នឹងតែ២ខែគេអាចយកយើងធ្វើជាងធ្វើអីបាន
បានលុយច្រើនដែលខាងម៉ាស៊ីត្រជាក់ហ្នឹងហើយតិចទៀតប្រទេសយើងរីកចំរើនទៅអញ្ចឹងគេត្រូវការអ្នកចេះជាងម៉ាស៊ីត្រជាក់ដែរដើម្មីលេងម៉ាស៊ីនត្រជាក់អីបានលុយច្រើនដែរ។

ខ៖ បាទ!ហ្នឹងហើយ។

ក៖ ចុះបើសិនជាបង បងស្គាល់មិត្តភក្រ័ដែលធ្វើខាងម៉ាស៊ីនត្រជាក់ហ្នឹងអត់ អត់ដែលជួប។

ខ៖ អត់តែជួប ជួបលើកមុខម៉ងយូរហើយខ្ញុំមិនហ៊ានទៅជិតគេមើលឃើញគេធ្វើ។

ក៖
ហ្នឹងហើយបើសិនជាបងថ្ងៃណាមួយបងឃើញមិត្តភក្រ័ហ្នឹងទៀតបងសួរគាត់ទៅអោយគាត់បង្រៀនទៅ។

ខ៖ ហ្នឹងហើយ។ អោយតែមានឳកាសជួប។

ក៖
ម៉េចៗដើររកគេខាងម៉ាស៊ីនត្រជាក់ទាល់តែបងដើររកកន្លែងណាដែលគេលាងម៉ាស៊ីត្រជាក់។

ខ៖ នៅលើគេមានដែរតើ។

ក៖ សាក់សួរគេសាក់មើល។

ខ៖
ឃើញគេដាក់លក់ម៉ាស៊ីនត្រជាក់ប៉ុន្តែមានពីរកន្លែងខ្ញុំមិនហ៊ានសួរគេអញ្ចឹងណាស់លោកគ្រូបើកន្លែងនោះលក់ដែរប៉ុន្តែមិនដឹងគេបង្រៀនអត់។

ក៖ ទាល់តែបងទៅកន្លែងគេជួសជុល
បើកន្លែងគេលក់ប្រហែលជាអត់មានប៉ុន្តែជាមានជាងគេប្រចាំ។

ខ៖ បាទ! ហ្នឹងហើយ។

ក៖
ប៉ុន្តែបើកន្លែងគេបង្រៀនហើយអាចរកការងារអោយយើងធ្វើទៀតដោយសារគេស្គាល់គ្នាអញ្ចឹងណាស់។

ខ៖ បាទ!។

ក៖ ហើយអញ្ចឹងចុះពេលដែលបងសាងសង់ផ្ទះបងមួយហ្នឹងបងចំណាយលុយអស់ប៉ុន្មាន។

ខ៖
អស់ប្រហែល៣០ម៉ឺនអីដែលនេះរោងបណ្តោះអាសន្នហ្នឹងរុសពីផ្ទះក្រោមខ្លះបានៗប៉ុណ្ណឹងរុសអាផ្ទះចាស់នៅក្រោម។

ក៖ ហើយចុះពេលដែលបងសាងសង់ផ្ទះមួយហ្នឹងបងត្រូវកាអីគេខ្លះដើម្បីសាងសង់។

ខ៖ ត្រូវការឈើ ដែកគោល តង់ ជញ្ជាំងគ្រប់សព្វបែបយ៉ាងដែរ។

ក៖ ចុះឧបករណ៍ប្រដាប់ប្រដាត្រូវការអីគេខ្លះ។

ខ៖ ពូថៅ ដែកគោះ អាណាតែប៉ុណ្ណឹង។

ក៖ អ៎!។

ខ៖ បាទ!។

កៈ អញ្ចឹងចុះពេលដែលបង ចុះឧបរកណ៍មួយហ្នឹងរកពីណាមកបងខ្ចីគេរឺក៏ម៉េចរបស់ខ្លួនឯង។

ខៈ របស់ខ្លួនឯងមានមួយជូនណាខ្ចីគេអ្នកជិះខាងទៅលោកគ្រូ។

កៈ អ៎! គេមានដែរ។

ខៈ បាទ! គេមាន។

កៈ ហើយចុះពេលដែលធ្វើរោងមួយហ្នឹងបងជួយគេធ្វើរឺបងធ្វើខ្លួនឯង។

ខៈ រកគេដែល។

កៈ រកគេដែរ។

ខៈ បាទ! រកគេអ្នកជិតខាងធ្វើ។

កៈ តែជួលគេអញ្ចឹងអស់លុយអត់។

ខៈ អស់យើងទិញអីអោយគេហូបតិចតួចហ្នឹង។ បាទ!
គេចេះតែអានឹតខ្ញុំលោកគ្រូគេឃើញខ្ញុំដលរើសអេតចាយ។

កៈ
អញ្ចឹងហើយចុះសំនួរចុងក្រោយចង់ថាអោយបងផ្ដែផ្ដាំទៅកូនបងរឺក៏ចៅៗបន្តទៀតបើសិនជាគាត់មានកូនក្មេងជំនាន់ក្រោយរឺអ្នកជិយខាងផ្សេងទៀតអោយគាត់ដើរតាមផ្លូវល្អផ្លូវអីអញ្ចឹងណាស់អោយគាត់បានរៀនសូត្រកុំអោយគាត់ទៅផ្លូវអីផ្សេងៗ។

ខៈ បាទ!។

កៈ អញ្ចឹងសូមអោយបងផ្ដល់ជាអនុសាសន៍បន្តិចមក។

ខៈ
ខ្ញុំសូមអោយប្អូនជំនាន់ក្រោយកុំដើរផ្លូវណាដែលសង្គមគេស្អប់ខ្ពើមដើរតាមផ្លូវដែលបានរៀនសូត្របានចេះដឹងកុំអោយដូចខ្ញុំពិបាកណាស់អត់ចេះល្ងឹតល្ងឹងរកមួយថ្ងៃហូបមួយថ្ងៃមិនមានមុ

ខរបរដូចគេល្អទេវាខ្វះខាត់ណាស់បើក្មេងសូមអោយក្មេងជំនាន់ក្រោយសូមអោយគេបានចេះដឹងបានរៀនសូត្រអោយបានល្អមានតែប៉ុណ្ណឹង។

ក៖ បាទ!

ហើយអញ្ចឹងអញ្ចេកថ្ងៃដែលខ្ញុំសំភាសន៍បងថ្ងៃនេះនៅថ្ងៃទី៩ខែ២ឆ្នាំ២០១៨អញ្ចឹងបងខ្ញុំសូមអរគុណបងដែលបានអោយសំភាសន៍ថ្ងៃនេះបងណាស់។ បាទ! អញ្ចឹងអរគុណច្រើន។